STATE OF WASHINGTON
**DEPARTMENT OF SOCIAL AND HEALTH SERVICES**
CHILD CARE SUBSIDY PROGRAMS (CCSP)

# លិខិតរង់ចាំតាមផ្ទះ / សាច់ញាតិនៃគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង (FFN)
## Family, Friend and Neighbor (FFN) In-Home / Relative Pending Letter

កាលបរិច្ឆេទ ៖ ____________________

____________________
លេខទូរស័ព្ទមជ្ឈមណ្ឌលទំនាក់ទំនងសេវាអតិថិជន

____________________
លេខទូរសារមជ្ឈមណ្ឌលទំនាក់ទំនងសេវាអតិថិជន

____________________
លេខសម្គាល់អតិថិជន

អ្នកបានស្នើសុំជំនួយពី Working Connections Child Care ឱ្យទូទាត់សម្រាប់ការថែទាំកុមារដែលបានផ្តល់ដោយណាមួយនៃ ៖

1. មិនមែនសាច់ញាតិ (មិត្តភក្តិ ឬអ្នកជិតខាង) ដែលមកផ្ទះរបស់អ្នកធ្វើការថែទាំ ឬ
2. សាច់ញាតិដែលមានសិទ្ធិ (គ្រួសារ) ក្នុងផ្ទះសាច់ញាតិ ឬសាច់ញាតិដែលមានសិទ្ធិដែលមកផ្ទះរបស់អ្នកធ្វើការថែទាំ។

**សូមអាន និងធ្វើតាមការណែនាំក្នុងផ្នែក 1 និង 2 នៃលិខិតនេះ។**

| **ផ្នែក 1. មុនពេលអនុញ្ញាតការទូទាត់ និងអនុម័តអ្នកផ្តល់សេវាដោយនាយកដ្ឋានកុមារ យុវជន និងគ្រួសារ (DCYF)** | |
|---|---|
| អ្នកផ្តល់សេវាគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង**ទាំងអស់ត្រូវតែ**មានអាយុ 18 ឆ្នាំ ឬចាស់ជាងនេះ។ ដើម្បីចាប់ផ្តើមដំណើរការការអនុម័ត អ្នកផ្តល់សេវាគ្រួសារ មិត្តភក្តិ និងអ្នកជិតខាង**ទាំងអស់**ត្រូវតែធ្វើតាមខាងក្រោម ៖<br>**ជំហាន 1.** បំពេញកម្រងព័ត៌មានអ្នកប្រើនៅក្នុងផតថលអ្នកផ្តល់សេវា WA Compass នៅ dcyf.wa.gov/services/early-learning-providers/ffn។<br>**ជំហាន 2.** បំពេញកម្រងព័ត៌មានអ្នកប្រើនៅក្នុង MERIT នៅ dcyf.wa.gov/services/earlylearning-profdev/merit។<br>**ជំហាន 3.** ពេលនៅក្នុង MERIT បំពេញការត្រួតពិនិត្យសាវតារចល័ត (PBC) និងទទួលការណែនាំលើរបៀបបំពេញដំណើរការស្នាមម្រាមដៃ។ ប្រើលេខនេះសម្រាប់ពាក្យសុំ និងស្នាមម្រាមដៃ PBC **ឥតគិតថ្លៃ** ៖ លេខពាក្យសុំ SU ៖ _____។ **សម្រាប់សំណួរនានា ទាក់ទង DCYF តាមលេខ 1-866-482-4325 ជម្រើស #8**។<br>**ជំហាន 4.** ផ្ញើ ឬអាប់ឡូតច្បាប់ចម្លងដែលអាចអានបានមួយនៃប័ណ្ណសន្តិសុខសង្គម និងអត្តសញ្ញាណប័ណ្ណមានរូបថតដែលចេញឱ្យដោយរដ្ឋាភិបាល ដូចជាប័ណ្ណបើកបរ អត្តសញ្ញាប័ណ្ណរដ្ឋវ៉ាស៊ីនតោន ឬលិខិតឆ្លងដែន នៅក្នុងផតថលអ្នកផ្តល់សេវា WA Compass នៅ ៖ dcyf.wa.gov/services/early-learning-providers/ffn<br>**ជំហានបន្ថែមត្រូវបានទាមទារ** សម្រាប់ការអនុម័តអ្នកផ្តល់សេវាដោយផ្អែកលើទំនាក់ទំនងទៅនឹងកុមារ និងកន្លែងដែលការថែទាំកើតមានឡើង។ | |
| **មិនមែនសាច់ញាតិ** | **សាច់ញាតិ** (គ្រួសារឈាមតែមួយ រៀបការ ឬក្រមគុលារការ) |
| អ្នកផ្តល់សេវាគឺមិនជាប់ទាក់ទងនឹងកុមារ និងជា ៖<br>a) មិត្តភក្តិ ឬ<br>b) អ្នកជិតខាងរបស់ឪពុក ឬម្តាយ។ | អ្នកផ្តល់សេវាគឺជាប់ទាក់ទងនឹងកុមារ និងជា ៖<br>a) បងប្អូនមនុស្សពេញវ័យដែលរស់នៅក្រៅផ្ទះរបស់កុមារ<br>b) ជីដូន ឬជីតា (ទួត និងឡួតផងដែរ)<br>c) ពូ ឬមីង (ទួត និងឡួតផងដែរ) ឬ<br>d) គ្រួសារផ្សេងទៀតដែលជាប់សាច់ឈាម រៀបការ ឬក្រមគុលារការ។ |
| ការថែទាំកុមារត្រូវបានអនុញ្ញាតឱ្យតែក្នុង**ផ្ទះ**របស់កុមារប៉ុណ្ណោះ។ | ការថែទាំកុមារត្រូវបានអនុញ្ញាតឱ្យតែក្នុងផ្ទះរបស់**អ្នកផ្តល់សេវា** ឬ**ផ្ទះ**របស់កុមារប៉ុណ្ណោះ។ |
| គ្មានតម្រូវការបន្ថែមសម្រាប់ការអនុម័តដំបូង – មើល **ផ្នែក 2** សម្រាប់តម្រូវការសម្រាប់ភាពមានសិទ្ធិទទួលកំពុងបន្ត | ប្រសិនបើការថែទាំគឺនៅក្នុង**ផ្ទះរបស់អ្នកផ្តល់សេវា** អ្នកផ្តល់សេវាត្រូវតែមានបុគ្គលម្នាក់ៗអាយុ 16 ឆ្នាំ និងចាស់ជាងនេះ ដែលរស់នៅជាមួយសាច់ញាតិ ក៏ត្រូវបំពេញជំហានទី 1, 2 និង 3 ខាងលើ។ |

**ផ្នែក 2. បន្ទាប់ពីការអនុម័តដោយ DCYF។ ការទូទាត់នឹងមិនចាប់ផ្តើម រហូតទាល់កាលបរិច្ឆេទដែលអ្នកផ្តល់សេវារបស់អ្នកត្រូវបានអនុម័ត ឬការថែទាំចាប់ផ្តើមដែលណាមួយមកក្រោយផង។ WAC 110-15-0125**

ដើម្បីនៅតែមានសិទ្ធិទទួលការទូទាត់ អ្នកផ្តល់សេវាមិនមែនសាច់ញាតិ (មិត្តភក្តិ និងអ្នកជិតខាង) និងជាសាច់ញាតិ (គ្រួសារ) ត្រូវតែ ៖

A. បំពេញ ក្នុងពេលកៅសិប (90) ថ្ងៃដំបូងនៃកាលបរិច្ឆេទចាប់ផ្តើមការទូទាត់ ការបណ្តុះបណ្តាលការតាមដានវត្តមានអេឡិចត្រូនិច DCYF។ ស្វែងរកព័ត៌មានបណ្តុះបណ្តាលនៅ dcyf.wa.gov/services/early-learning-providers/electronic-attendance-system/training ឬឱ្យប្រព័ន្ធតាមដានវត្តមានអេឡិចត្រូនិចរបស់អ្នកអនុម័តដោយ DCYF នៅ dcyf.wa.gov/services/early-learning-providers/electronic-attendance-system ។

B. ប្រើប្រព័ន្ធវត្តមានអេឡិចត្រូនិចប្រចាំថ្ងៃដើម្បីបញ្ចូលពេលវេលាចាប់ផ្តើម និងបញ្ចប់សម្រាប់ការថែទាំដែលបានផ្តល់ដល់កុមារម្នាក់ៗ និងប្រគល់កំណត់ត្រាអេឡិចត្រូនិចទៅ DCYF រាល់ខែ ដោយប្រើប្រព័ន្ធអេឡិចត្រូនិច។

C. រក្សាព័ត៌មានរបស់ពួកគេក្នុងផតថលអ្នកផ្តល់សេវា WA Compass និង MERIT ដែលបានអាប់ដេតជាមួយការផ្លាស់ប្តូរនានាទៅលើឈ្មោះស្របច្បាប់របស់ពួកគេ អាសយដ្ឋាន អ៊ីម៉ែល និងលេខទូរស័ព្ទ។ (**ផ្នែក 1** ៖ ជំហានទី 1 និង 2 លើទំព័រទីមួយ)

D. រក្សាការត្រួតពិនិត្យសាវតារចល័តរបស់ពួកគេដែលបានអាប់ដេត (តម្រូវឱ្យមានជារៀងរាល់ 3 ឆ្នាំ)។ (**ផ្នែក 1** ៖ ជំហានទី 1 និង 2 លើទំព័រទីមួយ)

ខាងក្រោមនេះគឺជា**តម្រូវការភាពមានសិទ្ធិកំពុងបន្តបន្ថែម** សម្រាប់អ្នកផ្តល់សេវា ផ្អែកលើទំនាក់ទំនងរបស់ពួកគេទៅនឹងកុមារ និងកន្លែងដែលការថែទាំកើតឡើង ៖

| អ្នកផ្តល់សេវា**មិនជាសាច់ញាតិ**<br>ការថែទាំកុមារគឺត្រូវបាន**អនុញ្ញាត**តែនៅក្នុង**ផ្ទះរបស់កុមារប៉ុណ្ណោះ** | អ្នកផ្តល់សេវា**ជាសាច់ញាតិ**ដែលមានសិទ្ធិទទួល<br>ការថែទាំកុមារគឺនៅក្នុង**ផ្ទះរបស់អ្នកផ្តល់សេវា** ឬ**កុមារ** |
|---|---|
| 1. ក្នុងពេល 90 ថ្ងៃដំបូងនៃកាលបរិច្ឆេទចាប់ផ្តើមទូទាត់ ចូរបំពេញ ៖<br>a) ការបណ្តុះបណ្តាលលើសុខភាព និងសុវត្ថិភាព DCYF ឬមានការផ្ទៀងផ្ទាត់នៃការលើកលែងការបណ្តុះបណ្តាល DCYF តាម WAC 110-16-0025(2)(b)។ ការបណ្តុះបណ្តាលលើសុខភាព និងសុវត្ថិភាព DCYF អាចរកឃើញលើបណ្តាញ នៅ ៖ dcyf.wa.gov/services/early-learning-providers/ffn;<br>b) បំពេញការបណ្តុះបណ្តាលជំនួយដំបូងទារក កុមារ និងមនុស្សពេញវ័យ និងការជួយដកដង្ហើមបេះដូង និងសួត (CPR)។<br>c) បញ្ចូលកាលបរិច្ឆេទបញ្ចប់នូវការបណ្តុះបណ្តាល CPR / ជំនួយដំបូង នៅក្នុង MERIT នៅ dcyf.wa.gov/services/earlylearning-profdev/merit។ ផ្ញើ ឬអាប់ឡូតភស្តុតាងនៃការបណ្តុះបណ្តាល CPR / ជំនួយដំបូង (ប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតគ្រូបង្រៀន) ទៅ DCYF នៅ dcyf.wa.gov/services/early-learning-providers/ffn<br>2. ក្នុងពេល 45 ថ្ងៃនៃការបញ្ចប់នៃការបណ្តុះបណ្តាលខាងលើ ផ្តល់ទៅ DCYF នូវកិច្ចព្រមព្រៀងសុខភាព និងសុវត្ថិភាពក្នុងផ្ទះ WCCC ដែលបានចុះហត្ថលេខាដោយអ្នកផ្តល់សេវា និងអ្នក ឪពុក (ឬម្តាយ) ដែលបង្ហាញថា ពួកគេបានពិភាក្សា និងពិនិត្យឡើងវិញនូវប្រធានបទ និងធាតុបញ្ហាប្រធានបទទាំងអស់ដែលមានក្នុងកិច្ចព្រមព្រៀងនេះ។ | 1. នៅពេលការថែទាំកុមារកើតឡើងក្នុងផ្ទះរបស់អ្នកផ្តល់សេវាជាសាច់ញាតិ បុគ្គលម្នាក់ៗអាយុ 16 ឆ្នាំ និងចាស់ជាងនេះ ដែល ៖<br>a) រស់នៅជាមួយអ្នកផ្តល់សេវាជាសាច់ញាត្តិ ត្រូវតែរក្សាការត្រួតពិនិត្យសាវតារចល័តរបស់ពួកគេ ដែលបានអាប់ដេត (ដែលបានតម្រូវជារៀងរាល់ 3 ឆ្នាំ)។<br>b) មានផែនការទៅរស់នៅជាមួយអ្នកផ្តល់សេវាជាសាច់ញាតិ ត្រូវតែមានការត្រួតពិនិត្យសាវតារចល័ត ដែលបានបំពេញមុនពេលផ្លាស់ទីចូលរស់នៅជាមួយអ្នកផ្តល់សេវា។<br>2. ចូលរួមក្នុងការហៅទូរស័ព្ទជំនួយបច្ចេកទេសក្នុងពេលកៅសិបថ្ងៃនៃកាលបរិច្ឆេទចាប់ផ្តើមទូទាត់ និងរៀងរាល់ឆ្នាំ បន្ទាប់ពីការហៅទូរស័ព្ទដំបូង។ តម្រូវការនេះអនុវត្តតែលើអ្នកផ្តល់សេវាជាសាច់ញាតិដែល**មិនមែនជា** ៖<br>a) បងប្អូនមនុស្សពេញវ័យដែលរស់នៅខាងក្រៅផ្ទះរបស់កុមារ;<br>b) ជីដូន-ជីតាទួត ឬជីដូន-ជីតាឡូត;<br>c) មីង ឬពូ។ |

| | |
|---|---|
| 3. ចូលរួមក្នុងការសួរទុក្ខប្រចាំឆ្នាំនៅផ្ទះរបស់កុមារជាមួយអ្នកឯកទេសលើកលែងអាជ្ញាប័ណ្ណ DCYF; និងនៅពេលអាចរកបាន អ្នក ឪពុក ឬម្តាយ។ គោលបំណងនៃការសួរសុខទុក្ខគឺដើម្បីធានាថា អ្នក និងអ្នកផ្តល់សេវាគឺអនុលោមតាមតម្រូវការសុខភាព និងសុវត្ថិភាព អង្កេតមើលបរិយាកាសថែទាំកុមារ និងទំនាក់ទំនងអ្នកផ្តល់សេវាជាមួយកុមារ និងពិភាក្សាលើការអនុវត្តសុខភាព និងសុវត្ថិភាព។<br>4. បំពេញការបណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពដែលបានអនុម័ត DCYF។ | |

ផ្នែក Child Care Aware ផ្តល់ព័ត៌មានឥតគិតថ្លៃ ឥតលំអៀង និងមានសេចក្តីយោងសម្រាប់គ្រួសារដែលកំពុងស្វែងរកការថែទាំកុមារដែលមានអាជ្ញាប័ណ្ណប្រកបដោយគុណភាពខ្ពស់។ ទូរស័ព្ទទៅលេខ 1-800-446-1114 ឬលើបណ្តាញនៅ childcareaware.org។

ដើម្បីស្វែងរកស្ថានភាពត្រួតពិនិត្យសារតាថែទាកុមារដែលមានអាជ្ញាប័ណ្ណ ប្រវត្តិចេញអាជ្ញាប័ណ្ណ របាយការណ៍តាមដាន ភាសាដែលបាននិយាយ និងច្រើនទៀត ចូលទៅកាន់ ៖ **ការត្រួតពិនិត្យការថែទាំកុមារ (Child Care Check) នៅ findchildcarewa.org**។

អ្នកអាចស្វែងយល់ថាតើការអភិវឌ្ឍទារក ឬកូនរបស់អ្នកស្ថិតក្នុងការតាមដាន ឬថាតើនាងត្រូវការការអនុវត្តបន្ថែមបន្តិចទៀតដើម្បីត្រៀមខ្លួនចូលរៀន។ ដើម្បីធ្វើដូច្នេះ អ្នកអាចបំពេញកម្រងសំណួរតាមដានការអភិវឌ្ឍអនុវត្តរបស់កុមារឥតគិតថ្លៃដោយទូរស័ព្ទទៅខ្សែបណ្តាញទាន់ហេតុការណ៍សុខភាពគ្រួសារ តាមលេខ 1-800-322-2588 ឬចូលទៅកាន់គេហទំព័រជំនួយមាតាបិតា 123 នៅ parenthelp123.org/child-development/help-me-grow-washington ដើម្បីស្វែងយល់បន្ថែមអំពីវា។

កុមារមានសិទ្ធិមនុស្សមូលដ្ឋានដើម្បីឱ្យមានសុវត្ថិភាព។ ការរំលោភបំពាន និងការមិនយកចិត្តទុកដាក់គំរាមកំហែងដល់សុវត្ថិភាពរបស់កុមារដោយដោយនាំពួកគេក្នុងហានិភ័យរបួសរាយកាយ ខាងអារម្មណ៍ និងសូម្បីតែដល់បាត់បង់ជីវិត។ បើអ្នកសង្ស័យថា កុមារម្នាក់គឺជាជនរងគ្រោះនៃការរំលោភបំពាន ឬការមិនយកចិត្តទុកដាក់ ចូរទូរស័ព្ទឥតគិតថ្លៃទៅ DSHS តាមលេខ 1-866-END-HARM (1-866-363-4276)។

**សូមទូរស័ព្ទទៅមជ្ឈមណ្ឌលទំនាក់ទំនងសេវាអតិថិជន ប្រសិនបើអ្នកមានសំណួរណាមួយអំពីជំហានបន្ទាប់ ឬភាពមានសិទ្ធិទទួលកំពុងបន្តរបស់អ្នក តាមលេខ 1-877-501-2233**។

**ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកមានសំណួរផ្សេងៗអំពីដំណើរការការអនុម័ត និងតម្រូវការនានា ឱ្យពួកគេទាក់ទងអ្នកឯកទេសលើកលែងអាជ្ញាប័ណ្ណរបស់ពួកគេ តាមលេខ ៖ 1-866-482-4325 #8 ឬផ្ញើអ៊ីម៉ែលទៅ dcyf.ffn@dcyf.wa.gov**។